.ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានអប់រំ
នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

# របាយការណ៍លទ្ធផល
# ស្ដីពី
# ការរៀបចំទិវាជាតិអំណានលើកទី ៧ ១១ មីនា ២០២២







វិទ្យាស្ថានជាតិអប់រំ
១១ មីនា ២០២២

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


មាតិកា....................................................................................................................១

សេចក្តីផ្តើម ...............................................................................................................៣

I. គោលបំណង...............................................................................................................៤

II. យុទ្ធវិធី....................................................................................................................៤

III. សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៧........................................៥

១. ដំណើរការរៀបចំទិវាជាតិអំណាន........................................................................ .................... ៥

ក.កិច្ចប្រជុំបច្ចេកទេសត្រៀមលក្ខណៈសម្បត្តិ..................................................................៥

ខ.ការរៀបចំលិខិតស្នាមគតិយុត្តិ.......................................................................................៥

២. ការប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងការប្រកួតប្រជែងជ្រើសរើស ............ ៦

ក.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រឡងប្រណាំងអានអត្ថបទ......................................៦

ខ.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រឡងប្រណាំងស្មូតកំណាព្យ.....................................៧

គ.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រឡងប្រណាំងតែងនិពន្ធ..........................................៨

ឃ.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុ បកស្រាយស្នាដៃអក្សរសិល្ប៍.......................................៩

៣. ការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២...........................................................១០

៣.១ កម្មវិធីពេលព្រឹក................................................................................................................១០

ក.របាយការណ៍វឌ្ឍនភាព ស្តីពី ការរៀបចំទិវាជាតិអំណាន.......................................................១១

ខ.សុន្ទរកថាបើកទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២...................................................១២

គ.ការប្រកាសលទ្ធផល និងប្រគល់ជូន..................................................................................១៣

ឃ.ការជូនលិខិតថ្លែងអំណរគុណ.........................................................................................១៥

ង.ការអានអត្ថបទ និងការស្មូតកំណាព្យដោយជ័យលាភីលេខ១..............................................១៦

ច.បាឋកថា ស្រាវជ្រាវ ស្តីពី " ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ "........... ...........១៦

៣.២ កម្មវិធីពេលរសៀល ...........................................................................................................១៨

ឆ. ការទស្សនាខ្សែវីដេអូ ស្តីពី ការរៀបចំ និងបើកដំណើរការបណ្ណាល័យបឋមសិក្សា..............១៨

ជ.ការស្មូតកំណាព្យរបស់បេក្ខជនជ័យលាភីលេខ ២ ផ្នែកស្មូតកំណាព្យ...............................១៩

ឈ. កិច្ចពិភាក្សាលើប្រធានបទ " អំណានដើម្បីលើកកម្ពស់ការអប់រំនៅកម្ពុជា "....................១៩

ញ. វេទិកា សំណួរ ចម្លើយ ..........................................................................................២២

ប្រសាសន៍ប្ូកសរុប និងបិទកម្មវិធី.............................................................................២៣

IV. សេចក្តីសន្និដ្ឋាន........................................................................................................២៥

V. ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ផ្នែកព័ត៌មាន និងគណៈកម្មការផ្សេងៗ សម្រាប់ទិវាជាតិអំណានលើកទី៧...............២៦

រូបភាពទី ១ លិខិតលេខ៤៤០ អយក.អកស ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២....................២៦

| | | |
|---|---|---|
| រូបភាពទី ២ | លិខិតលេខ ០៤ អយក.សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ | ២៧ |
| រូបភាពទី ៣ | លិខិតលេខ ០២ អយក.សសរ ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២២ | ២៨ |
| រូបភាពទី ៤ | លិខិតលេខ ៥៩៧ អយក.ឧទន ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២២ | ៣៤ |
| **ឧបសម្ព័ន្ធទី២** | ផ្នែកបញ្ជីឈ្មោះបេក្ខជន | ៣៥ |
| រូបភាពទី ៥ | ចំណាត់ថ្នាក់បេក្ខជនប្រឡងប្រណាំង អានអត្ថបទ | ៣៥ |
| រូបភាពទី ៦ | បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក " អានអត្ថបទ " | ៣៧ |
| រូបភាពទី ៧ | ចំណាត់ថ្នាក់បេក្ខជនប្រឡងប្រណាំង សូត្រកំណាព្យ | ៣៨ |
| រូបភាពទី ៨ | បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក " សូត្រកំណាព្យ " | ៤០ |
| រូបភាពទី ៩ | ចំណាត់ថ្នាក់បេក្ខជនប្រឡងប្រណាំង តែងនិពន្ធ | ៤១ |
| រូបភាពទី ១០ | បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក " តែងនិពន្ធ " | ៤៣ |
| រូបភាពទី ១១ | បញ្ជីឈ្មោះបេក្ខជនចូលរួមប្រកួតប្រជែង បកស្រាយស្នាដៃអក្សរសិល្ប៍ | ៤៤ |
| រូបភាពទី ១២ | បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែកប្រកួតប្រជែងបកស្រាយប្រធានបទ | ៤៧ |




## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី " **ទិវាជាតិអំណាន** " ក្រសួងអយក. បានយកចិត្តទុកដាក់សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា ដៃគូអភិវឌ្ឍ ស្ថាប័នឯកជន និងស្ថាប័នពាក់ព័ន្ធនានាតាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ រៀបចំប្រារព្ធទិវាជាតិអំណានបាន ៦លើករួចហើយ ចាប់តាំងពី ២០១៦មក។ ក្នុងការប្រារព្ធពិធីទិវាជាតិម្តងៗ ក្រសួងអប់រំ យុវជន និងកីឡា បានសហការរៀបចំឱ្យមានកម្មវិធីជាច្រើន មានដូចជា ការតាំងស្តង់ពិព័រណ៍សៀវភៅដែលបង្ហាញពីសមិទ្ធិផលក្នុងស្ថាប័នអប់រំ ជាស្នាដៃនិពន្ធរបស់វីរជនជាតិនិងអ្នកនិពន្ធល្បីៗ មានការនិទានរឿង ការប្រឡងប្រណាំងតែងនិពន្ធ ស្មូតកំណាព្យ និងអានអត្ថបទ សម្រាប់ទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងការប្រឡងជ្រើសរើសបេក្ខជន ជ័យលាភីដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទអក្សរសិល្ប៍ និងពិសេសមានវាគ្មិនល្បីៗ មកធ្វើបាឋកថាទៀតផង។ រាល់ការរៀបចំ និងប្រព្រឹត្តទៅនៃទិវាជាតិអំណានជារៀងរាល់ឆ្នាំ តែងមានការចូលរួម និងគាំទ្រពីមន្ត្រីរាជការ សិស្ស និស្សិត និងមហាជន ដែលមានបរិមាណកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ឆ្នាំ២០២១ កន្លងមក ទោះស្ថិតក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ និងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ក្រសួងអប់រំ យុវជន និងកីឡា នៅតែសហការរៀបចំទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ បានប្រព្រឹត្តទៅតាមអនឡាញដោយរលូន តាមកម្មវិធីដូចរៀងរាល់ឆ្នាំ។

ដោយឡែកឆ្នាំ ២០២២ នេះ ទោះបីស្ថិតក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ ប្រភេទថ្មី(អូមីក្រុង) ក្រសួងអប់រំ យុវជន និងកីឡា នៅតែយកចិត្តទុកដាក់រៀបចំទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ ក្រោមប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** " តាមអនឡាញ និងផ្សាយបន្តផ្ទាល់តាមគេហទំព័រ Facebook ផ្លូវការរបស់ក្រសួង បន្តផ្ទាល់ពីកន្លែងប្រារព្ធពិធីវិទ្យាស្ថានជាតិអប់រំ។ ដើម្បីញ៉ាំងឱ្យដំណើរការនៃទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២នេះ ប្រព្រឹត្តទៅបន្តបាននូវភាពអធិកអធម ក្រសួងបានរៀបចំនូវ ៖

១).ការប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសជ័យលាភីលេខ១ លេខ២ និងលេខ៣ សម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ។

២).ការប្រកួតប្រជែងបកស្រាយប្រធានបទ ស្តីពី " **តួនាទីអក្សរសិល្ប៍ពុទ្ធនិយម នៅសម័យក្រោយអង្គរ** " ដោយជ្រើសរើសបេក្ខជន បេក្ខនារី ជ័យលាភី៣រូប ដែលមានសមត្ថភាពការបកស្រាយប្រធានបទនេះ។

៣).យន្តការ និងកម្មវិធីសំខាន់ៗ នៃថ្ងៃប្រារព្ធពិធីទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ មានដូចជា ៖

- ការគោរពទង់ជាតិ និងការច្រៀងចម្រៀងបទពង្សាវតារខ្មែរ ដោយអ្នកចូលរួមទាំងអស់
- របាយការណ៍វឌ្ឍនភាព ស្តីពី ការរៀបចំទិវាជាតិអំណាន ចាប់ពីឆ្នាំ២០១៦ មកដល់ពេលនេះ
- សុន្ទរកថាបើក ការប្រារព្ធពិធីទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ ដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ការប្រកាសលទ្ធផលជ័យលាភីផ្នែក អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ សម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " និងជ័យលាភីផ្នែកបកស្រាយប្រធានបទស្នាដៃអក្សរសិល្ប៍
- ការអានអត្ថបទ និងស្មូតកំណាព្យ របស់បេក្ខជនជ័យលាភីលេខ១
- បាឋកថា ស្រាវជ្រាវ ស្តីពី " **ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ** " ដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- ការស្មូតកំណាព្យរបស់បេក្ខជនជ័យលាភី លេខ២
- ការទស្សនាខ្សែវីដេអូ ស្តីពី " ការរៀបចំ និងបើកដំណើរការបណ្ណាល័យបឋមសិក្សា និងសកម្មភាពអំណានទាំង៤ នៅក្នុងម៉ោងបណ្ណាល័យ "
- កិច្ចពិភាក្សាលើប្រធានបទ ស្តីពី " អំណានដើម្បីលើកកម្ពស់ការអប់រំនៅកម្ពុជា " ។

## I. គោលបំណង

ការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ ស្ថិតក្រោមប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** " មានគោលបំណង ៖

- បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ព្រមទាំងពង្រីកចំណេះដឹងដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
- រំលេចឱ្យឃើញពីតួនាទីរបស់អំណាន និងភាពពាក់ព័ន្ធរបស់អំណានជាមួយនឹងគុណភាពជីវិត លើគ្រប់ទិដ្ឋភាពនៅក្នុងដំណាក់កាលនៃការវិវឌ្ឍឈានទៅរកសង្គមឌីជីថល។

### ពាក្យស្លោកសម្រាប់ទិវាជាតិអំណាន លើកទី៧

១. ការអានជួយលើកកម្ពស់គុណភាពជីវិត
២. អំណានដើម្បីលើកកម្ពស់ការអប់រំនៅកម្ពុជា
៣. ការបណ្តុះទម្លាប់អានគឺ បានលើកកម្ពស់គុណភាពជីវិត
៤. អំណានដំបូង ជាមូលដ្ឋានគ្រឹះនៃបំណិនភាសា និងនវានុវត្តន៍
៥. យើងអានដើម្បីបង្កើនចំណេះដឹង
៦. ការអានបណ្តុះប្រាជ្ញា គុណវុឌ្ឍិ និងគុណធម៌
៧. ការអានប្តូរនិស្ស័យ លើកតម្លៃគុណជីវិត
៨. ការអានជាមូលដ្ឋាននៃបំណិនភាសា និងចំណេះដឹងសកល
៩. អំណត់ក្នុងអំណាន ជីវិតក្សាន្តក្នុងពុទ្ធិ
១០. ទំលាប់អានពិត ជីវិតរុងរឿង

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានលើកទី៧ ឆ្នាំ២០២២ ក្នុងដំណាក់កាលជំងឺកូវីដ-១៩ ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អ ក្រសួងអប់រំ យុវជន និងកីឡា មានយន្តការសំខាន់ៗ ជា៣ដំណាក់កាលគឺ ៖

ដំណាក់កាលទី១ ការប្រជុំពិភាក្សារៀបចំយុទ្ធវិធីអនុវត្ត និងការរៀបចំលិខិតបទដ្ឋានគតិយុត្តិ

ដំណាក់កាលទី២ ការប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ សម្រាប់ " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " និងការប្រកួតប្រជែងជ្រើសរើសបេក្ខជន ជ័យលាភី៣រូប សម្រាប់បកស្រាយប្រធានបទអក្សរសិល្ប៍

ដំណាក់កាលទី៣ ការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២៧ នៅវិទ្យាស្ថានជាតិអប់រំ និងបន្តតាមអនឡាញ។

## III. សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៧

### ១.ដំណើរការរៀបចំទិវាជាតិអំណាន

#### ក.កិច្ចប្រជុំបច្ចេកទេសត្រៀមលក្ខណៈសម្បត្តិ

កាលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដែលជានាយកដ្ឋានជំនាញបានរៀបចំកិច្ចប្រជុំ ជាមួយថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ បណ្ណាល័យជាតិ បណ្ណសារដ្ឋានជាតិ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងអង្គការដៃគូពាក់ព័ន្ធ សរុប ៧៣នាក់។ កិច្ចប្រជុំនេះ បានស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាពិគ្រោះយោបល់ការរៀបចំយន្តការ ប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ឆ្នាំ២០២២ ឱ្យប្រព្រឹត្តទៅដោយរលូន ប្រកបដោយគុណភាព និងប្រសិទ្ធភាព និងការសាទរពីមហាជន។ លទ្ធផលនៃកិច្ចប្រជុំនាពេលនោះមាន៖

- កំណត់បានប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** "
- ប្រធានបទបាឋកថា " ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ "
- ប្រធានបទកិច្ចពិភាក្សា ទី១ ៖ វិធីសាស្ត្រដឹកនាំសកម្មភាពអំណានក្នុងបណ្ណាល័យបឋមសិក្សា<br>ទី២ ៖ អំណានដើម្បីលើកកម្ពស់គុណភាពការអប់រំនៅកម្ពុជា<br>ទី៣ ៖ អំណានដើម្បីលើកកម្ពស់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- នីតិវិធីនៃការប្រឡងប្រណាំងការអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ដែលការងារនេះត្រូវបានដឹកនាំដោយ **លោកជំទាវ ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សារៀបចំសម្រាប់អនុវត្ត។
- ប្រធានបទ សម្រាប់ប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភី៣នាក់ បកស្រាយស្នាដៃអក្សរសិល្ប៍ " **តួនាទីអក្សរសិល្ប៍ពុទ្ធនិយម នៅសម័យក្រោយអង្គរ** "
- ការកំណត់ទីកន្លែងប្រារព្ធពិធី ធ្វើនៅវិទ្យាស្ថានជាតិអប់រំ និងសមាសភាពចូលរួមមិនឱ្យលើសពី ១០០នាក់ និងអ្នកផ្សេងទៀតប្រព្រឹត្តទៅតាមអនឡាញ។
- ការកំណត់ទីតាំង និងការរៀបចំ តាំងពិព័រណ៍សៀវភៅ។

#### ខ.ការរៀបចំលិខិតស្នាមគតិយុត្តិ

ក្រោមការដឹកនាំដោយ **លោកជំទាវ ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានរៀបចំលិខិតស្នាមគតិយុត្តិសំខាន់ៗ សម្រាប់ដំណើរការទិវាជាតិអំណានលើកទី៧ មានដូចខាងក្រោម ៖

- លិខិតលេខ ៤៤០ អយក.អកស ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ស្តីពី ការជម្រាបជូនថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីអនុវត្តសេចក្តីណែនាំលេខ៤៧ អយក.សណន ស្តីពី ការរៀបចំទិវាជាតិអំណាន១១ មីនា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ សម្រាប់ដំណើរការរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៧ ១១ មីនា ឆ្នាំ២០២២ ( រូបភាពទី១ ) ។
- លិខិតលេខ ០៤ អយក.សជណ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពី ការជម្រាបជូនសាធារណៈជន ក្នុងការប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភីចំនួន ៣ រូប ដើម្បីបកស្រាយប្រធានបទ " **តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ** " ( រូបភាពទី២ )។

- សេចក្តីសម្រេចលេខ ០២ អយក.សសរ ចុះថ្ងៃទី ០៣ ខែកម្ភៈ ឆ្នាំ២០២២ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំទិវាជាតិអំណាន (រូបភាពទី៣ )។
- លិខិតលេខ ៥៩៧ អយក.ឧទន ចុះថ្ងៃទី ០៣ ខែកម្ភៈ ឆ្នាំ២០២២ ស្តីពី ការចាត់តាំងថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ និងគណៈកម្មការវាយតម្លៃដាក់ពិន្ទុក្នុងការបកស្រាយប្រធានបទអក្សរសិល្ប៍ ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ ( រូបភាពទី៤ ) ។

## ២.ការប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងការប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភីបកស្រាយស្នាដៃអក្សរសិល្ប៍

ការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីលេខ១ លេខ២ លេខ៣ ផ្នែកអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ សម្រាប់ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងការប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភី៣រូប សម្រាប់បកស្រាយប្រធានបទ ស្តីពី " **តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ** " បានប្រព្រឹត្តទៅតាមអនឡាញ និងជួបប្រជុំនៅសាលប្រជុំនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា តាមពេលវេលា សកម្មភាព និងមានលទ្ធផល ដូចខាងក្រោម៖

### ក.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំង អានអត្ថបទ

ការវាយតម្លៃដាក់ពិន្ទុបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៤-៨ ខែមីនា ឆ្នាំ២០២២ មានខ្លឹមសារដូចខាងក្រោម ៖

**ក.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំង អានអត្ថបទ

| | | | | |
|---|---|---|---|---|
| ១. លោកជំទាវ | **ច័ន្ទ** | **ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ប្រធាន |
| ២. លោក | **ឃឹម** | **សារិន** | អនុប្រធាននា.អកស | អនុប្រធាន |
| ៣. លោក | **យ៉ង់** | **គំស៊ាន** | ប្រធានការិ.នា.អកស | សមាជិក |
| ៤. លោកស្រី | **ផាន់** | **សុជាតា** | មន្ត្រីនា.អកស | សមាជិក |
| ៥. លោក | **ពា** | **ឆួយ** | មន្ត្រី នា.អកស | លេខាធិការ |

**ក.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនទាំងអស់មកពី ២៤ រាជធានី ខេត្ត សរុប ២៤ នាក់ ក្នុងនោះស្រី ២៣ នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៥ និងទី៦ នៃសាលាបឋមសិក្សាចំណេះទូទៅ ( រូបភាពទី៥ )។

**ក.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកអានអត្ថបទ

. អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ ២ ពិន្ទុ
. សំឡេង សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូរបស់ពាក្យ ៣ ពិន្ទុ
. មិនខុសពាក្យ មិនរំលងពាក្យ ៤ ពិន្ទុ
. ឥរិយាបថសមរម្យ ១ ពិន្ទុ



**ក.៤** សកម្មភាពវាយតម្លៃដាក់ពិន្ទុ

ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការវាយតម្លៃបានជួបប្រជុំគ្នាធ្វើតាមអនឡាញ ដោយយកអត្ថបទដែលរាជធានីខេត្តទាំង២៤ បានបញ្ជូនផ្ញើមក ពិនិត្យ និងវាយដាក់ពិន្ទុជ្រើសរើស

យកបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងចំណោម បេក្ខជន២៤នាក់នោះ។




បេក្ខជនជ័យលាភី អានអត្ថបទ ទិវាជាតិអំណានលើកទី៧ ៖

**លេខ១ កុមារី ពិន ស្រីភ្លួង** ជាសិស្សរៀនថ្នាក់ទី៦ ប.បាក់ទូក រាជធានីភ្នំពេញ អានអត្ថបទ " អត្ថប្រយោជន៍នៃការអានសម័យឌីជីថល "

**លេខ២ កុមារី ណា ម៉ារ៉ានី** សិស្សរៀនថ្នាក់ទី៦ ប.រោងដំរី ខេត្តស្វាយរៀង អានអត្ថបទ " សៀវភៅជាឃ្លាំងនៃវិជ្ជា "

**លេខ៣ កុមារី ម៉ន ស្រីលាភ** សិស្សរៀនថ្នាក់ទី៦ ប.អង្គបក្សី ខេត្តតាកែវ អានអត្ថបទ " មាគ៌ាទៅកាន់អង្គរ "

(រូបភាពទី៦)

## ខ-ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំង ស្មូតកំណាព្យ

ការវាយតម្លៃដាក់ពិន្ទុបានប្រព្រឹត្តទៅពីថ្ងៃទី៤-៨ ខែមីនា ឆ្នាំ២០២២ មានខ្លឹមសារដូចខាងក្រោម៖

**ខ.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងផ្នែក ស្មូតកំណាព្យ

| | | | | |
|---|---|---|---|---|
| ១. លោកជំទាវ បណ្ឌិត | **សឿ** | **សុជាតា** | អនុរដ្ឋ.ក្រសួងអយក. | ប្រធាន |
| ២. ឯកឧត្តម | **យ៉ាន់** | **បូរិន** | ទីប្រឹក្សាក្រ.វប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣. លោកស្រី | **ម៉ៅ** | **តាន់ណារី** | អនុប្រធានការិ. នា.អកស. | សមាជិក |
| ៤. លោក | **ខិន** | **សុតារា** | អនុប្រធានការិ. នា.អកស. | សមាជិក |
| ៥. លោក | **ហ៊ិន** | **ឡាវ** | មន្ត្រី. នា.អកស. | លេខាធិការ |

**ខ.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥ រាជធានី ខេត្ត មាន ២៥នាក់ ក្នុងនោះស្រី ២២នាក់ ជាសិស្សរៀនថ្នាក់ទី៧,៨,៩ នៃសាលាមធ្យមសិក្សាចំណេះទូទៅ (រូបភាពទី៧ )។

**ខ.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកស្មូតកំណាព្យ

| | |
|---|---|
| . ស្មូតគោរពតាមលំនាំបទនៃកំណាព្យ | ៤ ពិន្ទុ |
| . ទឹកដមពីរោះក្រអៅក្រអួន | ៣ ពិន្ទុ |
| . សំឡេងមិនដាច់ មិនភ្លាត់ ឬមិនភ្លាវនាំឱ្យខុសចង្វាក់ | ២ ពិន្ទុ |
| . ទឹកមុខ កាយវិការទៅតាមបរិយាកាសនៃបទនីមួយៗ | ១ ពិន្ទុ |

**ខ.៤** សកម្មភាពវាយតម្លៃដាក់ពិន្ទុ



ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការបានជួបប្រជុំគ្នាតាមអនឡាញ ដោយយកវីដេអូរបស់បេក្ខជនជ័យ លាភីលេខ១ ដែលបានបញ្ជូនមកពីរាជធានី ខេត្តទាំង២៥ មកមើល ស្តាប់ ពិនិត្យនិងវាយតម្លៃដាក់ពិន្ទុ ដើម្បីជ្រើសយកបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងចំណោម២៥នាក់នោះ ។




បេក្ខជនជ័យលាភី ស្នូតកំណាព្យ ទិវាជាតិអំណានលើកទី៧ ៖

**លេខ១ កុមារី ងួន ឆេងងីម** សិស្សរៀនថ្នាក់ទី៩ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ខេត្តកំពង់ចាម កំណាព្យបទកាកគតិ សូត្របែបពុទ្ធបាទប្រាំហាន ចំណងជើង " **ពុទ្ធបាទប្រាំហាន៣វគ្គចុងក្រោយ** "

**លេខ២ កុមារី ហ៊ាង សុភត្រា** សិស្សរៀនថ្នាក់ទី៩ វិទ្យាល័យ ហ៊ុន សែន ខ្នារ ខេត្តត្បូងឃ្មុំ កំណាព្យបទកាកគតិ សូត្របែបពុទ្ធបាទប្រាំហាន ចំណងជើង " **តម្លៃអំណានក្នុងសម័យឌីជីថល** "

**លេខ៣ កុមារី ជ្រែង សៀវមី** សិស្សរៀនថ្នាក់ទី៩ វិ.ហ៊ុន សែន ឃ្លាំងលើ ខេត្តព្រះសីហនុ កំណាព្យបទកាកគតិ សូត្របែបពុទ្ធបាទប្រាំហាន ចំណងជើង " **អំណានជួយលើកកម្ពស់គុណភាពជីវិត ក្នុងសង្គមឌីជីថល** " (រូបភាពទី៨)។

**គ-ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំង តែងនិពន្ធ**

ការវាយតម្លៃដាក់ពិន្ទុ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥-៨ ខែមីនា ឆ្នាំ២០២២ មានខ្លឹមសារដូចខាងក្រោម៖

**គ.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងតែងនិពន្ធ

| | | | | |
|---|---|---|---|---|
| ១. ឯកឧត្តម | **ជ័យ** | **ចាប** | ទីប្រឹក្សារាជរដ្ឋាភិបាល | ប្រធាន |
| ២. លោកជំទាវ | **ទន់** | **សារ៉ឹម** | អនុរដ្ឋលេខាធិការក្រសួងអយក. | អនុប្រធាន |
| ៣. លោក | **ឃិន** | **ធី** | អនុប្រធាននាយកដ្ឋាន.អកស | សមាជិក |
| ៤. លោក | **ម៉ែន** | **សុន** | សាស្ត្រាចារ្យផ្នែកនិពន្ធ | សមាជិក |
| ៥. លោក | **ព្រៃ** | **សំបូរ** | អនុប្រធានការិយាល័យនា.អកស | សមាជិក |
| ៦. លោក | **ដាំ** | **ចេង** | មន្ត្រីនា.អកស | លេខាធិការ |

**គ.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥ រាជធានី ខេត្ត សរុបមាន ២៥នាក់ក្នុងនោះស្រី ១៦នាក់ ជាសិស្សរៀននៅថ្នាក់ទី ១០,១១,១២ នៃវិទ្យាល័យចំណោះទូទៅ (រូបភាពទី៩)។

**គ.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកតែងនិពន្ធ

. អត្ថរូប រចនាបទ (វង្វាស់កាព្យ ចំណាប់ជួនភាសាកាព្យ ) ៣ ពិន្ទុ

. អត្ថន័យ ( ត្រឹមត្រូវតាមប្រធានបទ ) ៣ ពិន្ទុ

. អត្ថរស ( តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌ ) ៣ ពិន្ទុ

. អក្ខរាវិរុទ្ធ ១ ពិន្ទុ



**គ.៤** សកម្មភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ

១.ការវាយតម្លៃអត្ថបទរបស់បេក្ខជនទាំងអស់ ដែលបានបញ្ជូនមកពី២៥រាជធានីខេត្ត ពិនិត្យ វាយតម្លៃ តម្លៃជ្រើសរើសបានអ្នកមានពិន្ទុខ្ពស់ជាងគេ ១០នាក់។

២.ការវាយតាមអនឡាញលើបេក្ខជន១០នាក់

ក្រោមការត្រួតពិនិត្យផ្ទាល់ពី គណៈកម្មការវាយតម្លៃនិងដាក់ពិន្ទុ។




បេក្ខជនជ័យលាភី តែងនិពន្ធ ទិវាជាតិអំណានលើកទី៧ ៖

**លេខ១ កុមារី ជោ ស្រីណាង** សិស្សរៀនថ្នាក់ទី១២ វិទ្យាល័យ ហ៊ុនសែន ពងទឹក ខេត្តស្វាយរៀង តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា " **អំណានជួយលើកកម្ពស់ជីវិតក្នុងសង្គមឌីជីថល** "

**លេខ២ កុមារី ឈើវ គឹមលេង** សិស្សរៀនថ្នាក់ទី១២ វិទ្យាល័យ ហ៊ុនសែន ចំការដូង ខេត្ត កែប តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា " **អំណានជួយលើកកម្ពស់ជីវិតក្នុង សង្គមឌីជីថល** "

**លេខ៣ កុមារា ឡោ សុជា** សិស្សរៀនថ្នាក់ទី១២ វិទ្យាល័យ ជា ស៊ីម ឈូកវ៉ា រាជធានីភ្នំពេញ តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា "**ស្មាតឌីជីថល** " (រូបភាពទី១០)។

**ឃ.ក្រុមគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ការបកស្រាយស្នាដៃអក្សរសិល្ប៍**

ការវាយតម្លៃដាក់ពិន្ទុ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៦-១០ ខែមីនា ឆ្នាំ២០២២ មានខ្លឹមសារដូចខាងក្រោម៖

**ឃ.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រកួតប្រជែងបកស្រាយស្នាដៃអក្សរសិល្ប៍

| | | | |
|---|---|---|---|
| ១. ឯកឧត្តម បណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខា.ក្រសួង អយក. | ប្រធាន |
| ២. លោកជំទាវ | **ទន់ សាអ៊ីម** | អនុរដ្ឋ.ក្រសួង អយក. | អនុប្រធាន |
| ៣. លោក | **យិន ធី** | អនុប្រ.នាអយស. | សមាជិក |
| ៤. លោក | **ទ្រៃ សំបូរ** | អនុប្រ.កាវិ.នា.អកស | សមាជិក |
| ៥. លោក | **សុខ បញ្ញាវឌ្ឍន៍** | មន្ត្រី នា.អកស | លេខាធិការ |

**ឃ.២** បេក្ខជនចូលរួមប្រកួតប្រជែង

បេក្ខជនមកពី២៥ រាជធានី ខេត្ត មាន៤០ នាក់ក្នុងនោះស្រី ១២នាក់ ជាគ្រូបង្រៀន សិស្ស និស្សិត និងជាបុគ្គលិក ស្ថាប័នវិស័យឯកជន (រូបភាពទី១១)។

**ឃ.៣** សកម្មភាពវាយតម្លៃដាក់ពិន្ទុ

- ការប្រជុំតាមអនឡាញធ្វើអត្រាកំណែ ។ ខ្លឹមសាររួមរបស់អត្រាកំណែមាន ៖



. សេចក្តីផ្តើម ១ ពិន្ទុ
. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ពុទ្ធនិយម ១ ពិន្ទុ
. សង្គមបញ្ហានៅសម័យក្រោយអង្គរ ១ ពិន្ទុ
. តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ ៥ ពិន្ទុ
. សន្និដ្ឋាន ១ ពិន្ទុ
. រចនាបថ ១ ពិន្ទុ



- ការវាយតម្លៃលើកិច្ចការរបស់បេក្ខជន ៖

. គណៈកម្មការបានយកកិច្ចការបេក្ខជនទាំងអស់ មកពិនិត្យ វាយតម្លៃដាក់ពិន្ទុ ក្នុងនោះជ្រើសរើសបានបេក្ខជន១០នាក់ ពិន្ទុខ្ពស់ជាងគេ ។

. ការជ្រើសរើសបេក្ខជនដែលមានសមត្ថភាពខ្ពស់ ៣ នាក់ សម្រាប់ធ្វើការបកស្រាយប្រធានបទ ស្ដីពី " **តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ** " ។

ជ័យលាភី បេក្ខជនបកស្រាយ ប្រធានបទ ក្នុងកម្មវិធីទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២







**ជ័យលាភីលេខ ២**
លោក **ទឹម សុខហួយ** ជាគ្រូបង្រៀន វិ. ស.អ.ហ.ស អង្គតាសោម ខេត្តត.ក

**ជ័យលាភីលេខ ១**
លោក **ជក់ សុភា** ជាគ្រូបង្រៀន ស.ជំនាន់ថ្មី វិ.ព្រែកលាប ភ្នំពេញ

**ជ័យលាភីលេខ ៣**
លោក **មី សុវណ្ណ** ជាគ្រូបង្រៀន វិ.បាត់ដឹង ខេត្តកំ.ស្ពឺ (រូបភាពទី១២)

## ៣.ការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២

### *៣.១ កម្មវិធីពេលព្រឹក*



ការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១មីនា ២០២២ បានប្រព្រឹត្តទៅនាថ្ងៃ សុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ក្រោមប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** " នៅសាលប្រជុំវិទ្យាស្ថានជាតិអប់រំ និងតាមអនឡាញ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទទីស្ដីការ មន្ទីរអយក.រាជធានី ខេត្ត តាមតំណ Zoom https://fb.me/e/Y7V0SImO សរុប៥០០នាក់ ។

ទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២ បានប្រព្រឹត្តទៅតាមកម្មវិធី មានសកម្មភាព ខ្លឹមសារដូចខាងក្រោម៖

## ក. របាយការណ៍វឌ្ឍនភាព ស្តីពី ការរៀបចំទិវាជាតិអំណាន



បន្ទាប់ពីការគោរពទង់ជាតិ និងច្រៀងចម្រៀងបទពង្សាវតាខ្មែររួចមក លោក **ស៊ុន ម៉ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានបង្ហាញពីវឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណានជូនអង្គពិធីថា បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី ទិវាជាតិអំណានរួចមក ក្រសួងអយក. បានសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍរៀបចំទិវាជាតិអំណានបាន ៦ លើករួចមកហើយ មានៈ

- លើកទី១ ឆ្នាំ២០១៦ ក្រោមប្រធានបទ " **បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន** " មានអ្នកចូលរួម ១,៨៨៣ នាក់ ដែលជាតួលេខ តាមឆ្នាំកំណើតរបស់សម្តេចសង្ឃរាជ **ជួន ណាត** និងបានប្រព្រឹត្តទៅនៅស.ភ.ព ដោយមានកម្មវិធីអាននិទានរឿង អានអត្ថបទ និងសូត្រកំណាព្យជានិម្មិតរូប និងមានការតាំងពិព័រណ៌សៀវភៅ ១៨ ស្តង់ ដែលកម្មវិធីទាំងអស់នេះផ្តើមឡើងដើម្បីដាស់អារម្មណ៍ដល់ប្រជាជនកម្ពុជាឱ្យចូលចិត្តអាន និងបណ្តុះទម្លាប់អាន ។

- លើកទី២ ឆ្នាំ២០១៧ ក្រោមប្រធានបទ " **អានដើម្បី ភាពសុខដុមនៃជីវិត** " មានអ្នកចូលរួម ១,៨៥០ នាក់ ដោយមានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យជាលើកដំបូង នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ព្រមទាំងមានស្តង់តាំងពិព័រណ៌សៀវភៅ ៣៣ស្តង់ ដែលគ្រប់គ្រងដោយ ២៨ ស្ថាប័ន និងមានអ្នកចូលរួមទស្សនា និងជាវសៀវភៅប្រមាណជាង ៣០.០០០ នាក់។

- លើកទី៣ ឆ្នាំ២០១៨ ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " មានអ្នកចូលរួម ៣,៩៦៦ នាក់។ ឆ្នាំទី៣នេះ ក៏មានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យដើម្បីទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ការរៀបចំស្តង់ថតរូប ស្តង់ពិព័រណ៌សៀវភៅ២៧ស្តង់ និងមានវាគ្មិនល្បីៗ មកធ្វើបាឋកថាទៀតផង។

- លើកទី៤ ឆ្នាំ២០១៩ ក្រោមប្រធានបទ" **ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត** " មានអ្នកចូលរួម ៤,០០០នាក់ មានកម្មវិធីប្រកួតប្រជែងអាន សូត្រកំណាព្យ និងតែងនិពន្ធ នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ដោយជ្រើសចេញពីសិស្ស ៣ភូមិសិក្សាដដែល។ កម្មវិធីនេះ គណៈកម្មការបានរៀបចំស្តង់ថតរូប ស្តង់ពិព័រណ៌សៀវភៅ៦៧ស្តង់ មានអ្នកចូលរួមទស្សនា និងជាវសៀវភៅកើនដល់ ៦៧.០០០នាក់។ ក្នុងឱកាសនៃទិវានោះ មានការចែកនូវឯកសារជាស្នាដៃនិពន្ធរបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជូនដល់អ្នកចូលរួមដោយឥតគិតថ្លៃ ។

- លើកទី៥ ឆ្នាំ២០២០ ក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " មានអ្នកចូលរួម ២៥០០ នាក់។ ដូចឆ្នាំកន្លងមកដែរ ក្រសួងបានរៀបចំឱ្យមានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យ និងការតែងនិពន្ធ នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " និងមានការជ្រើសរើសបេក្ខជនជ័យលាភីបកស្រាយប្រធានបទស្នាដៃអក្សរសិល្ប៍ ដែលបានជ្រើសចេញពីមន្ត្រីអប់រំ និងមហាជនសម្រាប់ជាវាគ្មិនកិត្តិយស។

ទិវាអំណានជាតិលើកទី៥នេះ ក្រសួងបានរៀបចំឱ្យមានសិក្ខាសាលា ស្តីពី " អំណានដំបូង ", " ស្តង់ជាវបណ្ណាល័យ " និងយុទ្ធនាការ ស្តីពី " តោះអានរាល់ថ្ងៃ " ដែលបានប្រព្រឹត្តទៅរយៈពេល១០ ថ្ងៃ ជាពិសេសស្តង់តាំងពិព័រណ៌សៀវភៅកើនដល់១០៤ ស្តង់ ចូលរួមដោយក្រុមហ៊ុន និងស្ថាប័នចំនួន ៨០។

- លើកទី៦ ឆ្នាំ២០២១ ទោះបីស្ថិតក្នុងបរិបទនៃជំងឺកូវីដ-១៩ និងព្រឹត្តិការណ៍ ២០កុម្ភៈ ២០២១ នៃជំងឺ

កូវីដ-១៩ ថែមទៀត ក៏ក្រសួងអយក.នៅតែពុះពារ បានរៀបចំទិវាជាតិអំណាន ក្រោមប្រធានបទ " **អំណានក្នុងបរិបទកូវីដ-១៩** " តាមអនឡាញទាំងស្រុង ដោយមានការរៀបចំកម្មវិធីប្រឡងប្រណាំងអាន សូត្រកំណាព្យ និងការតែងនិពន្ធ នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់ សម្ដេចតេជោ ហ៊ុន សែន** " និងការប្រកួតប្រជែងជ្រើសរើសបេក្ខជនជ័យលាភីបកស្រាយប្រធានបទស្នាដៃអក្សរសិល្ប៍ដូចបណ្ដារាល់ឆ្នាំដែលធ្វើតាមអនឡាញ និងឯការតាំងពិព័រណ៍សៀវភៅក៏ត្រូវបានរៀបចំតាមអនឡាញ ដោយក្រុមយុវជនស្ម័គ្រចិត្តផងដែរ។

ដោយឡែកឆ្នាំ២០២២នេះ ទោះស្ថិតក្នុងដំណាក់កាលប្រឈមនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលមានមេរោគប្រភេទថ្មីអូមីក្រុង ក៏រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា បានបើកបវេសនកាលឆ្នាំសិក្សា ២០២១-២០២២ ពិសេស ការប្រារព្ធទិវាជាតិអំណានលើកទី៧ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ក្រោមប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** " បានប្រព្រឹត្តឡើងនៅវិទ្យាស្ថានជាតិអប់រំដោយមានការចូលរួមផ្ទាល់ និងតាមអនឡាញសម្រាប់អ្នកចូលរួមពីចម្ងាយ រាជធានី ខេត្ត។

**ខ.សុន្ទរកថាបើកទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២**



ប្រសាសន៍របស់**ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ក្នុងឱកាសនៃពិធីបើកទិវាជាតិអំណានលើកទី៧ ១១មីនា ២០២២ មានខ្លឹមសារ ដូចខាងក្រោម៖

. កិច្ចស្វាគមន៍ដ៏ស្មោះស្ម័គ្រចំពោះអ្នកពាក់ព័ន្ធ និងមហាជនក្នុងការចូលរួមទស្សនា និងតាមដានការប្រារព្ធទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២១ ដែលកំពុងធ្វើឡើងតាមអនឡាញ។

. *ក្នុងគោលបំណងរំឭកដល់វីរភាព និងគុណូបការៈដ៏ថ្លៃថ្លារបស់* ***សម្ដេចព្រះសង្ឃរាជ ជួន ណាត*** *ដែលបានខិតខំតស៊ូ ពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរ និងក្នុងគោលបំណងបណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ព្រមទាំងពង្រីកចំណេះដឹងដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។*

. ការប្រារព្ធទិវាជាតិអំណានលើកទី៧ ស្ថិតក្រោមប្រធានបទ " **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** " *ក្នុងគោលបំណង រំលេចឱ្យឃើញពីតួនាទីរបស់អំណាន និងភាពពាក់ព័ន្ធរបស់អំណានជាមួយនឹងគុណភាពជីវិត លើគ្រប់ទិដ្ឋភាពនៅក្នុងដំណាក់កាលនៃការវិវឌ្ឍឆ្ពោះទៅកេសង្គមឌីជីថល។*

. ក្រសួងអប់រំ យុវជន និងកីឡា បានចាត់ទុកសមត្ថភាពអានរបស់សិស្សនៅក្នុងកម្រិតថ្នាក់ដំបូង គឺជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពដទៃទៀត ។

. ក្រសួងបានចេញប្រកាសដាក់ឱ្យអនុវត្ត " **កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង** " នៅទូទាំងប្រទេស ព្រមទាំងបានដាក់បញ្ចូលក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូ តាមសាលាគរុកោសល្យទាំងអស់តាមប្រព័ន្ធ ១២+២ និង ១៤+២។

ដើម្បីជំរុញ និងពន្លឿន ការពង្រីកការអនុវត្ត "កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង " នៅទូទាំងប្រទេស **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានដាក់ចេញនូវអនុសាសន៍ ដូចខាងក្រោម៖

- *គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត, ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ, កម្រងសាលារៀន និងសាលាបឋមសិក្សាទូទាំងប្រទេស ត្រូវចូលរួមពង្រឹង និងពង្រីកការអនុវត្ត*

*កញ្ចប់ សម្ភារៈអំណានថ្នាក់ដំបូង តាមរយៈការរៀបចំវគ្គបំប៉នដោយផ្ទាល់, ការបំប៉នតាមបែបចម្រុះ និងប្រព័ន្ធអនឡាញ ព្រមទាំងផ្តល់ការគាំទ្រ តាមរូបភាពការផ្តល់ប្រឹក្សាគរុកោសល្យ។ រៀបចំបង្កើតបណ្ណាល័យនៅសាលារៀនដែលមិនទាន់មាននិងពង្រឹងដំណើរការបណ្ណាល័យ ចំពោះ សាលារៀនដែលមានបណ្ណាល័យរួចហើយ ស្របតាមសេចក្តីណែនាំប្រតិបត្តិ ស្តីពី ស្តង់ដាបណ្ណាល័យបឋមសិក្សា។*

- *លោកគ្រូ អ្នកគ្រូ បង្រៀនថ្នាក់ទី១ និងទី២ ទាំងអស់ ត្រូវចូលរួមអនុវត្ត " កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង " តាមរយៈការចូលរួមវគ្គបំប៉នរបស់ក្រសួង,មន្ទីរអប់រំ យុវជន និងកីឡា, គ្រឹះស្ថានបណ្តុះ បណ្តាលគ្រូ, អង្គការដៃគូពាក់ព័ន្ធ និងធ្វើការសិក្សាស្វែងយល់អំពីកញ្ចប់សម្ភារៈនិងវិធីសាស្ត្របង្រៀនអំណានថ្នាក់ដំបូងតាមរយៈវីដេអូបង្រៀន ដែលក្រសួងបានផលិត និងផ្តល់ជូននាពេលកន្លងមក ព្រមទាំងអាចទាញយក កញ្ចប់សម្ភារៈអំណាន និងវីដេអូការបង្រៀនពីក្នុងគេហទំព័រ និង App ផ្លូវការនានារបស់ក្រសួង។ ចូលរួមបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍសមត្ថភាពជាប្រចាំ និងសហការជាមួយទីប្រឹក្សាគរុកោសល្យដើម្បីកែលម្អសកម្មភាពបង្រៀននិងរៀន និងការគ្រប់គ្រងថ្នាក់រៀនឱ្យកាន់តែមានប្រសិទ្ធភាព។*
- *មាតាបិតា អ្នកអាណាព្យាបាលសូមចូលរួមតាមដានលទ្ធផលសិក្សា, អត្តចរិត, សីលធម៌, សុជីវធម៌របស់កូនក្នុងគ្រួសារ, សាលារៀន និងក្នុងសហគមន៍ ព្រមទាំងជួយបង្រៀនកូនបន្ថែមនៅផ្ទះ និងចូលរួមអានសៀវភៅជាមួយកូនជាដើម។ បន្ថែមលើសពីនេះ មាតាបិតា អ្នកអាណាព្យាបាល ត្រូវផ្គត់ផ្គង់សម្ភារៈសិក្សា, ទិញកញ្ចប់សម្ភារៈអំណានឱ្យកូនបានហ្វឹកហាត់នៅផ្ទះ, ចូលរួមគាំទ្រជាសម្ភារៈ ថវិកាដល់ដំណើរការបណ្ណាល័យនៅតាមសាលារៀន, ការអភិវឌ្ឍសាលារៀន និងគាំទ្រដល់គ្រូបង្រៀនជាដើម។*

ទីបញ្ចប់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន គ្រឹះស្ថានសិក្សា និងពិសេសគណៈកម្មការរៀបចំទិវាជាតិអំណានគ្រប់លំដាប់ថ្នាក់ដែលបានរៀបចំឱ្យពិធីនេះមានដំណើរការល្អប្រសើរដោយទទួលបានផ្លែផ្កានិងរលូនតាម កម្មវិធីបានគ្រោងទុក។

## គ.ការប្រកាសលទ្ធផល និងប្រគល់ជូន " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " , ប្រកាសនីយបត្រពានរង្វាន់ និងប្រាក់រង្វាន់លើកទឹកចិត្ត ជូនដល់បេក្ខជនជ័យលាភីថ្នាក់ជាតិ

### ជ័យលាភី ផ្នែកអានអត្ថបទ



**លេខ១ កុមារី ពិន ស្រីក្លូង** សិស្សរៀនថ្នាក់ទី៦ ប.បាក់ទូក រាជធានីភ្នំពេញ ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៣.០០០.០០០៛



**លេខ២ កុមារី ណា ម៉ារ៉ានី** សិស្សរៀនថ្នាក់ទី៦ ប.ពោងដំរី ខេត្តស្វាយរៀង ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ២.០០០.០០០៛



លេខ៣ កុមារី ម៉ន ស្រីលាភ សិស្សរៀនថ្នាក់ទី៦ ប.អង្គបក្សី ខេត្តតាកែវទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ១.០០០.០០០ ៛

## ជ័យលាភី ផ្នែកស្មូតកំណាព្យ



លេខ១ ងួន ឆេងងីម រៀនថ្នាក់ទី៩ វិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ខេត្តកំពង់ចាម ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៤.០០០.០០០ ៛



លេខ២ កុមារី ហ៊ាង សុភត្រា រៀនថ្នាក់ទី៩ វិទ្យាល័យ ហ៊ុន សែន ខ្នារ ខេត្តត្បូងឃ្មុំ ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៣.០០០.០០០ ៛



លេខ៣ កុមារី ជ្រេង សៀវមី រៀនថ្នាក់ទី៩ វិទ្យាល័យ ហ៊ុន សែន ឃ្លាំង ខេត្តព្រះសីហនុ ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ២.០០០.០០០ ៛

## ជ័យលាភី ផ្នែកតែងនិពន្ធ



លេខ១ កុមារី ជោ ស្រីណាង រៀនថ្នាក់ទី១២ វិ. ហ៊ុនសែន ពងទឹក ខេត្តស្វាយរៀង ទទួលបាន៖

. " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៦.០០០.០០០ ៛



**លេខ២ កុមារី ឈើវ គឹមលេង** រៀនថ្នាក់ទី១២ វិ. ហ៊ុនសែន ចំការដូង ខេត្ត កែប ទទួលបាន៖

. " **ពានរង្វាន់ សម្ដេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៥.០០០.០០០៛



**លេខ៣ កុមារា ឡោ សុជា** រៀនថ្នាក់ទី១២ វិ. ជា ស៊ីម ឈូកវ៉ា រាជធានីភ្នំពេញ ទទួលបាន៖

. " **ពានរង្វាន់ សម្ដេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រពានរង្វាន់ ១

. ប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៤.០០០.០០០៛

## ជ័យលាភី ផ្នែកបកស្រាយប្រធានបទអក្សរសិល្ប៍







| | | |
|---|---|---|
| **ជ័យលាភីលេខ ២** | **ជ័យលាភីលេខ ១** | **ជ័យលាភីលេខ ៣** |
| លោក **ទឹម សុខហួយ** គ្រូបង្រៀន | លោក **ជក់ សុភា** គ្រូបង្រៀន | លោក **មី សុវណ្ណ** គ្រូបង្រៀន |
| វិ.ស.អ.ហ.ស អង្គតាសោម ខេត្តត.ក | សា.ជំនាន់ថ្មី វិ.ព្រែកលាប រាជធានីភ.ព | វិ.បាត់ដឹង ខេត្តកំពង់ស្ពឺ |
| . ប្រ.នីយបត្រជ័យលាភី កិត្តិយស ១ | ប្រ.នីយបត្រជ័យលាភី កិត្តិយស ១ | ប្រ.នីយបត្រជ័យលាភី កិត្តិយស |
| ១រង្វាន់លើកទឹកចិត្ត ២.០០០.០០០៛ | រង្វាន់លើកទឹកចិត្ត ១.៥០០.០០០៛ | រង្វាន់លើកទឹកចិត្ត ១.០០០.០០០៛ |

### ឃ.ការជូនលិខិតថ្លែងអំណរគុណ

ក្នុងឱកាសនៃទិវាជាតិអំណានលើកទី៧ ១១មីនា ២០២២ នេះ ក្រសួងបានរៀបចំ និងផ្តល់ជូន លិខិតថ្លែងអំណរគុណ ដល់អ្នកដែលបានសហការឧបត្ថម្ភ និងពាក់ព័ន្ធមួយចំនួន មានដូចជា ៖







**១. អង្គការមូលនិធីអាស៊ី**

ឧបត្ថម្ភថវិកាចំនួន៥០០ ដុល្លា សម្រាប់បោះពុម្ពអារឃើតក្នុង ទិវាជាតិអំណានលើកទី៧

**២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់**

ឧបត្ថម្ភ Kindle White  Paper ចំនួន៩ កញ្ចប់ សម្រាប់បេក្ខជនជ័យលាភី ៩នាក់ ( អាន ស្មូត និងតែងនិពន្ធ )

**៣.អង្គការ Room to Read**

ឧបត្ថម្ភគាំទ្រ ដល់ការថត និង ផលិតវីដេអូ អំណានទាំង៤ ក្នុងបណ្ណាល័យ

## ង.ការអានអត្ថបទនិងស្មូតកំណាព្យ ដោយជ័យលាភីលេខ១



**កុមារី ពិន ស្រីភួង** ជាសិស្សរៀនថ្នាក់ទី៦ បឋមសិក្សាបាក់ទូក រាជធានីភ្នំពេញ  ជាជ័យលាភីលេខ១ ផ្នែកអានអត្ថបទ បានអានអត្ថបទ  មានចំណងជើងថា ៖

" **អត្ថប្រយោជន៍នៃការអានសម័យឌីជីថល** "



**កុមារី ងួន ឆេងឆីម** សិស្សថ្នាក់ទី៩ វិ.ប៊ុនរ៉ានី ហ៊ុន សែន ស្ពឺ ខេត្តកំពង់ចាម  ជាជ័យលាភីលេខ១ ផ្នែកស្មូតកំណាព្យ បានស្មូតកំណាព្យ បទកាកគតិ សូត្របែបពុទ្ធបាទប្រាំឋាន មានចំណងជើងថា៖

" **អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល** "

ជាស្នាដៃនិពន្ធរបស់កុមារី **ជោ ស្រីណាង** ជាជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ ។

## ច. បាឋកថា ស្រាវជ្រាវ ស្តីពី " ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ "



ក្រៅពីភារកិច្ចដឹកនាំ កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ប្រកបដោយគតិបណ្ឌិត **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានស្រាវជ្រាវចងក្រង បាន ឯកសារជាស្នាដៃយ៉ាងច្រើន សម្រាប់សិស្ស និស្សិត និងសាធារណៈ ធ្វើជាមូលដ្ឋានសិក្សាបន្ថែមទៀត។

ជាក់ស្តែង ក្នុងកម្មវិធីទិវាជាតិអំណានលើកទី៧ ១១ មីនា ឆ្នាំ២០២២ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានធ្វើបាឋកថា ស្រាវជ្រាវ ស្តីពី " **ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ** " ដែលជាស្នាដៃនិពន្ធទី៣៤ របស់លោក និងមានខ្លឹមសារសំខាន់ ដូចខាងក្រោម៖

ភាសា ជានវានុវត្តន៍ដ៏សំខាន់មួយរបស់មនុស្សជាតិ អាចឱ្យមនុស្សផ្ទេរចំណេះដឹង និងបង្កើតពុទ្ធិដើម្បីជួយកែលម្អជីវភាពរស់នៅរបស់មនុស្សជាតិ និងជាមូលដ្ឋានគ្រឹះនៃអារ្យធម៌ ពិសេសវិទ្យាសាស្ត្រ និងបច្ចេកទេស រួមទាំងសិល្បៈផងដែរ។ ការអភិវឌ្ឍភាសា គឺជាដំណើរការនៃការវិវត្តបន្តិចម្តងៗចាប់តាំងពីកុមារភាព ត្រូវរៀននិយាយ និងទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន ជាពិសេសកុមារចាប់ផ្តើមរៀននិយាយ បន្ទាប់ពីការលូតលាស់ខួរក្បាល។ នៅពេលដែលកុមាររៀននិយាយ ខួរក្បាលកុមារក៏បន្តការអភិវឌ្ឍ និងរីកលូតលាស់ដែរ។ ដើម្បីចេះអាន កុមារត្រូវមាន

ការអភិវឌ្ឍផ្នែកគំហើញ ពិសេសសរសៃប្រសាទភ្នែក និងការអភិវឌ្ឍផ្នែកស្តាប់ និងសរីរាង្គឥន្ទ្រីយ៍ដទៃទៀត។ បន្ទាប់ពីរៀននិយាយហើយ កុមារត្រូវរៀនសរសេរ ដែលទាមទារនូវការអភិវឌ្ឍសរីរាង្គផ្សេងៗរបស់កុមារ ដូចជាសាច់ដុំដៃជើង ។ល។

ភាសាជានវានុវត្តន៍សង្គមដ៏សំខាន់បំផុត ដែលជួយលើកស្ទួយមនុស្សជាតិឱ្យមានចំណេះដឹងខ្ពស់ និងមានសមត្ថភាពគ្រប់គ្រងលើអ្វីៗ ស្ទើរតែទាំងអស់នៅជុំវិញខ្លួន និងក៏ជាមធ្យោបាយទាក់ទងមនុស្សនៅក្នុងសម័យកាលជាមួយគ្នា និងជាមធ្យោបាយផ្ទេរព័ត៌មានពីមនុស្សជំនាន់មុន ទៅមនុស្សច្រើនជំនាន់ទៅអនាគត។

ដូចនេះ ការសិក្សា ការអភិវឌ្ឍភាសារបស់កុមារទាមទារនូវការយល់ដឹង អំពីការអភិវឌ្ឍរាងកាយ ការអភិវឌ្ឍសតិបញ្ញា ការអភិវឌ្ឍសង្គម និងទ្រឹស្តី ផ្សេងៗទៀតនៃការអភិវឌ្ឍរបស់កុមារ ។

ទាក់ទងនឹងខ្លឹមសារខាងលើនេះ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានបង្ហាញពីវិធីសាស្ត្រមួយចំនួនសម្រាប់ជួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការបង្រៀនសិស្ស តាមកូមិសិក្សានីមួយៗ ដូចខាងក្រោម ៖

### ១.សម្រាប់ការបង្រៀននៅមត្តេយ្យសិក្សា

. បង្រៀនសិស្សដោយប្រើប្រាស់វត្ថុ និងសម្ភារៈឧបទេស ដែលជាក់ស្តែង និងដោយប្រើប្រាស់ពណ៌ ដើម្បីឱ្យកុមារបុរេប្រតិបត្តិអាចយល់បាន។

. និយាយខ្លីៗ និងប្រើសកម្មភាពមួយៗ ក្នុងពេលតែមួយ ដោយប្រើប្រាស់វិធីបង្រៀន ជាពាក្យសំដីផង និងបង្ហាញពីសកម្មភាពផង ជាពិសេសបង្រៀនតាមរយៈល្បែង ដើម្បីឱ្យក្មេងយល់។

. ដើម្បីកាត់បន្ថយ " មជ្ឈត្តនិយម " គ្រូត្រូវបង្រៀនឱ្យកុមារស្វែងយល់ ពីអារម្មណ៍ និងមតិយោបល់អ្នកដទៃ និង បង្រៀនឱ្យចេះចែករំលែក និងឱ្យចេះពីររបៀបរបបខ្ចី និងឱ្យក្មេងឯទៀត ខ្ចីរបស់លេង។

. បង្រៀនកុមារឱ្យមានបំណិនជាក់ស្តែង ដើម្បីអាចរៀនបំណិនស្មុគស្មាញ ដូចជារៀនអានពាក្យសាមញ្ញនិងរៀនលេងជាមួយក្មេងឯទៀត ដើម្បីបណ្តុះបំណិនសកល ។

. ផ្តល់ឱកាសឱ្យក្មេងមានបទពិសោធន៍ច្រើន ដើម្បីពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់យល់ពីទស្សនទានថ្មីៗ និងការរៀន ភាសា ដូចជានាំកុមារទៅមើលសួនសត្វ ចូលបណ្ណាគារ ស្តាប់រឿងនិទានស្តាប់ភ្លេង និងបង្រៀនកុមារ ឱ្យចេះរៀបរាប់ពីសកម្មភាព ដែលគេបានធ្វើ បានស្តាប់ បានឃើញ បានភ្លក្សរស់ជាតិជាដើម។

### ២. សម្រាប់ការបង្រៀនកម្រិតបឋមសិក្សា

. បន្តបង្រៀនដោយប្រើប្រាស់វត្ថុ និងសម្ភារៈ ដែលជាក់ស្តែង ជាពិសេសនៅពេលបង្រៀនមេរៀនពិបាកៗ

. បន្តផ្តល់ឱកាសឱ្យក្មេងបានធ្វើពិសោធន៍ជាមួយវត្ថុផ្សេងៗ

. បង្រៀនកុមារដោយប្រើបទបង្ហាញ និងអត្ថបទខ្លីៗ ដោយរៀបចំតាមលំដាប់លំដោយ

. ប្រើប្រាស់ឧទាហរណ៍ងាយៗ ដែលសិស្សធ្លាប់រៀន ដើម្បីពន្យល់គំនិតធំៗ

. ផ្តល់ឱ្យសិស្សធ្វើចំណាត់ថ្នាក់ និងបែងចែកតាមក្រុមនៃវត្ថុ និងគំនិត ដោយអនុវត្ត ពីកម្រិតងាយៗ ទៅកម្រិតពិបាកៗ

. ប្រើប្រាស់វិធីសាស្ត្របង្រៀន ឱ្យសិស្សរៀនគិតតាមបែបឡូស៊ិក និងវិភាគបញ្ហា

### ៣. សម្រាប់ការបង្រៀននៅកម្រិតមធ្យមសិក្សា

. បន្តបង្រៀនសិស្សដោយប្រើយុទ្ធសាស្ត្របង្រៀន និងសម្ភារៈដែលជាក់ស្តែង

. បន្តផ្តល់ឱកាសដល់សិស្សសាកល្បងធ្វើសម្មតិកម្ម

. ផ្តល់ឱកាសដល់សិស្សដោះស្រាយបញ្ហា និងគិតតាមបែបវិទ្យាសាស្ត្រ

. បង្រៀនបញ្ញត្តិធំៗ ដោយប្រើប្រាស់ព្រឹត្តិការណ៍ជាក់ស្តែងមកគាំទ្រ ដោយប្រើប្រាស់ឯកសារ និងគំនិត ដែលសមស្របជាមួយនឹងគំនិតរបស់សិស្ស។

ខ្លឹមសារបាឋកថា ស្រាវជ្រាវ ស្តីពី " ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ " បង្ហាញពីការយកចិត្តទុកដាក់ខ្ពស់លើការងារគ្រប់គ្រង ដឹកនាំ និងចិត្តសប្បុរសធម៌របស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ដោយបានប្រមូលទ្រឹស្តីសំខាន់ៗ របស់ភាសាវិទូ និងចិត្តវិទូល្បីៗ ពីជុំវិញពិភពលោក មកសិក្សាប្រៀបធៀប និងឆ្លុះបញ្ចាំង ពីដំណើរអភិវឌ្ឍខួរក្បាល និងប្រព័ន្ធប្រសាទ ទាក់ទងនឹងភាសារបស់មនុស្ស សំដៅជួយបង្កើនសមត្ថភាព និងចែករំលែកឈានទៅរកពុទ្ធិបញ្ញាពិតប្រាកដ ជូនដល់លោកគ្រូ អ្នកគ្រូ មាតាបិតា អ្នកអាណាព្យាបាល និងមហាជនទូទៅ ពីដំណើរវិវត្តខួរក្បាល ភាសា ទាក់ទងនឹងការអប់រំកុមារ។

## *៣.២ កម្មវិធីពេលរសៀល*

### ធ.ការទស្សនាខ្សែ វីដេអូ ស្តីពី " ការរៀបចំ និងបើកដំណើរការបណ្ណាល័យបឋមសិក្សា និងសកម្មភាពអំណានទាំង៤ នៅក្នុងម៉ោងបណ្ណាល័យ "

ជាកិច្ចចាប់ផ្តើមនៃកម្មវិធីពេលរសៀល អង្គពិធីទាំងមូល បានទស្សនាខ្សែវីដេអូ ស្តីពី " ការរៀបចំ និងបើកដំណើរការបណ្ណាល័យបឋមសិក្សា និងសកម្មភាពអំណានទាំង៤នៅក្នុងម៉ោងបណ្ណាល័យ" ។ វីដេអូនេះត្រូវបានសហការផលិតដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការ រូមធូរីដ ក្នុងការរៀបចំចំថតមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖



**វីដេអូទី១** បង្ហាញពី " ការរៀបចំនិងបើកដំណើរការបណ្ណាល័យបឋមសិក្សា" ដើម្បីឱ្យការរៀបចំ គ្រប់គ្រង និងដំណើរការបណ្ណាល័យបានប្រព្រឹត្តទៅដោយរលូន និងជោគជ័យ ត្រូវផ្អែកលើឯកសារចំនួន៣គឺ ១.ការបង្កើតនិងគ្រប់គ្រង ២.សកម្មភាពអំណានក្នុងបណ្ណាល័យ និង ៣. បញ្ជីសៀវភៅរឿងកុមារ។



**វីដេអូទី២** បង្ហាញពីសកម្មភាព " អំណានឮ "

ខ្លឹមសារផ្តោតសំខាន់លើការចូលរួមរបស់កុមារមានដូចជា៖

. មុនពេលអាន ត្រូវប្រាប់សិស្សឱ្យទៅរកសៀវភៅ ប្រាប់ចំណងប្រាប់ពាក្យគន្លឹះ បង្កើតបញ្ហាសម្រាប់ឱ្យសិស្សគិត

. ពេលអាន គ្រូដឹកនាំអាន ដោយអានជាមួយសិស្ស និងការអានផ្សារ ភ្ជាប់ជាមួយរូបភាព។

. ក្រោយពេលអាន សួរសំណួរបញ្ជាក់ រំលឹកលើខ្លឹមសារមេរៀន



**វីដេអូទី៣** បង្ហាញពី " អំណានចូលរួម " មានគោលបំណង ៖

១. លើកទឹកចិត្តឱ្យចាប់អារម្មណ៍ក្នុងការអាន

២. ផ្តល់ជាគម្រូល្អនៃរបៀបអានដល់សិស្ស

៣ . ណែនាំពីប្រភេទផ្សេងៗគ្នានៃរឿងដល់សិស្ស

៤. លើកទឹកចិត្តសិស្សឱ្យអានជាបរិយាកាសឱ្យជួយគាំទ្រ

៥. លើកកម្ពស់ទម្លាប់នៃការអាន



**វីដេអូទី៤** បង្ហាញពី " អំណានដៃគូ "

អំណានដៃគូ ជាសកម្មភាពរបស់សិស្សក្នុងការចាប់ដៃគូគ្នាដោយស្មគ្រចិត្ត និងធ្វើការជ្រើសរើសសៀវភៅសមស្របជាមួយភាពអាន ជាទីពេញចិត្តរបស់ពួកគេ ក្រោមការដឹកនាំរបស់គ្រូថ្នាក់ នៅក្នុងម៉ោងបណ្ណាល័យ។



**វីដេអូទី៥** បង្ហាញពី " អំណានបុគ្គល "

អំណានបុគ្គលជាសកម្មភាពអានរបស់សិស្សម្នាក់ៗ នៅក្នុងម៉ោងបណ្ណាល័យ ក្រោមការគ្រប់គ្រងរបស់គ្រូប្រចាំថ្នាក់ ឬបណ្ណារក្ស

. មុនពេលអាន សិស្សជ្រើសរើសសៀវភៅយកមកអានដោយស្មគ្រចិត្ត និងសួរគ្រូពេលជួបពាក្យពិបាក

. ពេលអាន គ្រូតាមដាន ពិនិត្យ និងស្តាប់ ការអានរបស់សិស្សម្នាក់ៗ

. ក្រោយពេលអាន ឱ្យសិស្សឡើងចែករំលែកពីអ្វីដែលគាត់បានអាន

**ជ.ការសូត្រកំណាព្យរបស់បេក្ខជនជ័យ លាភីលេខ២ ផ្នែកសូត្រកំណាព្យ**



**កុមារី ហ៊ាង សុភត្រា** ជាជ័យលាភីលេខ២ ផ្នែកសូត្រកំណាព្យ បានសូត្រកំណាព្យបទ កាកគតិ សូត្របែប ពុទ្ធបាទប្រាំឋាន មានចំណង

" **អំណានក្នុងសម័យឌីជីថល** " ជាស្នាដៃនិពន្ធរបស់កុមារី **ឈឺវ គឹមលេង** ជាជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ។

**ឈ.កិច្ចពិភាក្សាលើប្រធានបទ " អំណានដើម្បីលើកកម្ពស់ ការអប់រំនៅកម្ពុជា "**



កម្មវិធីកិច្ចពិភាក្សានេះ ត្រូវបានអញ្ជើញចូលរួមជាពីវាគ្មិន៤រូប ក្នុងនោះមាន ៖

១. ឯ.ឧ **បណ្ឌិត សិត សេខ** នា.វិទ្យា.គរុ. ភ.ព

២. លោក **បណ្ឌិត សំអេ អង្គារ័ត្ន** អគ្គ.រងនៃអគ្គ.គ/នប

៣. លោក **ព្រីង មរកត** ប្រ.នា.មចទ

៤. លោក **ហោ សុខៈ** នាយកកម្មវិធីអំណាននៃអង្គការរូមធូរីដ

កិច្ចពិភាក្សានេះ ត្រូវបានសម្របសម្រួលដោយលោកស្រី **បណ្ឌិត មួ ច័ន្ទគុលិកា** ប្រធាននាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ យុវជន និងកីឡា។

ក. គោលបំណងនៃកិច្ចពិភាក្សា

- ជជែក ពិភាក្សា ទៅលើបញ្ហាប្រឈមដែលធ្វើឱ្យសិស្សមិនចង់អាន(មិនរីករាយនឹងការអាន )
- ពិនិត្យមើលលើអន្តរាគមន៍ និងឧត្តមានុវត្តន៍ ដែលបានអនុវត្តកន្លងមក ដែលធ្វើឱ្យសិស្សចង់អាន ( រីករាយនឹងការអាន ) នៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងនៅក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ( កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងកម្មវិធីអភិវឌ្ឍជាប្រចាំរបស់គ្រូបង្រៀន )
- កំណត់យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព ក្នុងបរិបទនៃបរិវត្តកម្មសង្គមឌីជីថល ដើម្បីធ្វើឱ្យសិស្សរីករាយ នឹងការអាន។

ខ. បរិបទ និងទស្សទាន

- បរិបទនៃសង្គមកម្មឌីអីថល ការអានដើរតួនាទីយ៉ាងសំខាន់ ដើម្បីលើកកម្ពស់ការអប់រំសិស្ស និងធ្វើឱ្យគេទទួលបានជោគជ័យក្នុងជីវិតការងារនាពេលអនាគត។
- ភ័ស្តុតាងជាច្រើនដែលបានមកពីការស្រាវជ្រាវ បង្ហាញថា សិស្សចូលចិត្តអានខ្លាំង ជាអ្នកដែលមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរនៅក្នុងថ្នាក់រៀន និងទំនោរទៅរកភាពជោគជ័យនាពេលអនាគតខ្ពស់ ប្រៀបធៀបជាមួយសិស្សដែលមិនចូលចិត្តអាន។
- ការស្រាវជ្រាវរបស់ OECD 2012 បានរកឃើញថា ភាពរីករាយនឹងការអានរបស់សិស្ស មានទំនាក់ទំនងខ្លាំងជាមួយនឹងការសិក្សារបស់សិស្ស ជាជាងជាមួយស្ថានភាពសេដ្ឋកិច្ច សង្គមទៅទៀត និងក៏បង្ហាញផងដែរថា អត្រាដែលរីករាយនឹងការអានរបស់សិស្ស មានការធ្លាក់ចុះនៅតំបន់អឺរ៉ុប ណូហ្វែលស្សេឡង់ កូរ៉េខាងត្បូង ជប៉ុន និងប្រទេសអាស៊ីផ្សេងៗទៀត ។
- រាជរដ្ឋាភិបាល និងក្រសួងអយក. បានចេញនូវវិធានការ គោលនយោបាយ និងអន្តរាគមន៍ជាច្រើន ដើម្បីលើកកម្ពស់ការអាននៅកម្ពុជា ក្នុងនោះរាជរដ្ឋាភិបាលបានចេញអនុក្រឹតលេខ ១២០ អនក្រ .បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ដោយកំណត់យកថ្ងៃទី១១ ខែមីនា ជាថ្ងៃប្រារព្ធទិវាជាតិអំណាន។ ចាប់ពីពេលនោះមក ក្រសួងអយក. តែងបានរៀបចំទិវាជាតិអំណាននេះជារៀងរាល់ឆ្នាំ។ ព្រឹត្តិការណ៍នេះ បានបង្ហាញពីនិន្នា ការណ៍នៃការចង់អាន និងការរីករាយនឹងការអាន ហាក់មានសន្ទុះកើនឡើងនៅកម្ពុជា រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែអត្រាសិស្សដែលរីករាយនឹងការអាន នៅតែមានកម្រិតទាបនៅឡើយ ។

គ. សកម្មភាព និងលទ្ធផលនៃកិច្ចពិភាក្សា

**សំណួរទី I** តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យសិស្សមិនចង់អាន ពិសេសសិស្សនៅកម្រិតបឋមសិក្សា ?

ចម្លើយ . មិនមានសៀវភៅច្រើនកម្រិត និងមិនមានច្រើនប្រភេទ

. មិនមានម៉ោងកំណត់ជាផ្លូវការ ក្នុងការកំណត់ឱ្យសិស្សអាន

សំណួរ តើហេតុអ្វី បានជាសិស្សមិនរីករាយ នៅក្នុងការអានជាពិសេសសិស្ស កម្រិតមធ្យមសិក្សា

ចម្លើយ . នាយកដ្ឋានមធ្យមសិក្សា បានបណ្តុះសិស្សឱ្យមានបំណិនក្នុងការអាន អានស្ទាត់ អានយល់វាក្យស័ព្ទ អានយល់អត្ថន័យដើម្បីផ្សារភ្ជាប់ចំណេះដឹងជាមួយជីវភាពប្រចាំថ្ងៃ នៅក្នុងសេដ្ឋកិច្ចសង្គម

. បណ្តុះសិស្ស ឱ្យសប្បាយនឹងការអានដើម្បីឱ្យលទ្ធផលសិក្សាប្រសើរឡើង គឺពឹងផ្អែកលើសៀវភៅសិក្សាគោលតាមរយៈការបង្កើតកម្រងសំណួរ ការបបួលសិស្សឱ្យស្រង់ព័ត៌មាន

យកស្នាដៃទុកបណ្ណាល័យ និងការគាំទ្រការវាយតម្លៃ។

. អ្វីដែលបង្កើនការសប្បាយនឹងការអាន គឺការបង្កើនឱ្យសិស្សមានសៀវភៅសិក្សាគោល

. ជាពិសេស នៅដំណាក់កាលកូវីដនេះ ជាដំណាក់កាលមួយដែលត្រូវលើកទឹកចិត្តអាន

សំណួរ តើមានបញ្ហាប្រឈមអ្វីខ្លះសម្រាប់គរុសិស្សទាក់ទង នឹងការមិនចង់អាន ?

ចម្លើយ កត្តាដែលនាំឱ្យសិស្ស គរុសិស្សមិនរីករាយ នឹងការអានសៀវភៅ អាចបណ្តាលមកពី

កត្តាសង្គម៖ ម្នាក់ៗចូលចិត្តសម្ភារៈ

កត្តាសាលារៀន៖ គ្រូបង្រៀនមិនដឹកនាំ និងមិនជាគម្រូក្នុងការអាន , បណ្ណាល័យមិនសមស្រប,វិធីសាស្ត្របង្រៀនមិនបានកំណត់ឱ្យសិស្សអានសៀវភៅ,កម្មវិធីអានសៀវភៅ មិនបានកំណត់ចូលក្នុងកាលវិភាគ

កត្តាគ្រួសារ៖ កញ្ចប់អំណានមិនទាន់ជ្រួតជ្រាបដល់គ្រួសារ, ការទំលាប់អានរបស់គ្រួសារ

កត្តាបុគ្គល ៖ មិនមានឧបនិស្ស័យ , ខ្វះការកសាងទម្លាប់អានពីតូច ពីគ្រួសារ

សំណួរ តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យសិស្សមិនចង់អាន ផ្តោតលើលក្ខណៈជាប្រព័ន្ធ?

ចម្លើយ . កត្តាសំខាន់តើលោកគ្រូ អ្នកគ្រូ គាត់បានចំណាយពេលអានសៀវភៅជាលក្ខណៈបុគ្គលបានប៉ុន្មាននាទី និងការអានសម្រាប់ការងារបានប៉ុន្មាននាទីក្នុងមួយថ្ងៃ?

. ការអាននាំឱ្យមានសន្តិភាពផ្លូវចិត្ត

. គ្រូនៅបឋមសិក្សាសំខាន់ គឺត្រូវបំផុស និងដឹកនាំសិស្សឱ្យមានទម្លាប់អានសៀវភៅ

. សិស្សដែលដល់ថ្នាក់ទី៧ ហើយមិនចេះអានសៀវភៅ ជាមុខសញ្ញាប្រឈមនឹងការបោះបង់ការសិក្សា

. ការអាននាំឱ្យមានអាយុវែង និងកាន់តែអាននាំឱ្យកាន់តែចង់អាន

**សំណួរទី II** តើមានវិធីសាស្ត្រ និងប្រសិទ្ធភាពអ្វីខ្លះបានដាក់ចេញ ដើម្បីលើកកម្ពស់ក្នុងកម្រិតនៃការអាន?

ចម្លើយ . ទម្លាប់ ៖ គ្រួសារត្រូវបង្កើតទំលាប់ដល់សិស្សក្នុងការអាន មានសៀវភៅអាន មានកម្មវិធីអាន

. បំណិនអាន ៖ ប្រើកញ្ចប់អំណាន អំណានឮ មានរបស់អាន

. បង្កើតគម្រូអានដើម្បីបង្ហាញឱ្យឃើញថាកាអានពិតជាសប្បាយនោះកុមារពិតជាចូលចិត្តអាន

. មនុស្សសំខាន់ក្នុងការដឹកនាំការអានពេលនេះ គឺបណ្ណារក្ស ដើម្បីដឹកនាំជួយដល់កុមារ

. ប្រព័ន្ធសេវាកម្មគាំទ្រឱ្យមានការអាន រួមទាំងសៀវភៅ ទាំងបរិយាកាស

សំណួរ តើមានការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន និងការវាតម្លៃការសិក្សាសិស្សយ៉ាងដូចម្តេច?

ចម្លើយ . អានសៀវភៅមួយបង្កើតសៀវភៅមួយ ហើយឈរលើមូលដ្ឋាននៃការវាយតម្លៃ

. វាយតម្លៃការសិក្សារបស់សិស្សនៅដើមឆ្នាំ វាស់ស្ទង់កម្រិតយល់ដឹងងាយរៀបចំការបង្រៀន

. វាយតម្លៃសំខាន់ដើម្បីជម្រុញការអានរ ការផ្លាស់ប្តូររបៀបគ្រប់គ្រង និងវធីសាស្ត្របង្រៀន

សំណួរ តើមានផលជះអ្វីខ្លះលើការអាន និងតើអាចជួយលើកកម្ពស់ស្តង់ដាវិជ្ជាជីវៈដូចម្តេច?

ចម្លើយ . កម្មវិធីអក្ខរកម្មអំណាន៖ បណ្តុះបណ្តាលសិស្សឱ្យចេះអាន ជម្រុញការអានបែបស្រាវជ្រាវ គឺជួបគ្រូ១ម៉ោង រៀនខ្លួនឯង១ម៉ោង ។

. ចប់ឆ្នាំទី៤ គរុសិស្សត្រូវសរសេររបាយការណ៍ស្រាវជ្រាវប្រតិបត្តិ

១. ពង្រឹងចំណេះដឹងវិជ្ជាជីវៈ អានដើម្បីបានចំណេះដឹង ចំណេះដឹងបានទូលាយ

២. ប្រតិបត្តិវិជ្ជាជីវៈ   មានចំណេះដឹងខ្ពស់នាំឱ្យប្រតិបត្តិបានល្អ

៣. ការសិក្សាវិជ្ជាជីវៈ អានជាចលករជួយនាំឱ្យមានការអភិវឌ្ឍជាប្រចាំ

៤. សីលធម៌វិជ្ជាជីវៈ  មានចំណេះដឹង មានវិជ្ជាជីវៈ  នាំឱ្យមានសីលធម៌វិជ្ជាជីវៈល្អ

សំណួរ  តើក្រសួងអយក. គួររៀបចំគោលនយោបាយអ្វីខ្លះ ដើម្បីលើកកម្ពស់ការអានរបស់សិស្ស?

ចម្លើយ  . ការសិក្សាពីគោលនយោបាយដែលមានស្រាប់ ពិនិត្យឡើងវិញ កែលម្អ ចុះផ្ទាល់ដល់សាលារៀន ដោយពិនិត្យមើលចាប់ពីថ្នាក់មូលដ្ឋាន ផ្សារភ្ជាប់គ្រប់ជាតុទាំងអស់ដើម្បីកែលម្អ។

៣. វេទិកាសំណួរចម្លើយ

១. លោកជំទាវ  **ទន់ សារ៉ឹម**



សំណួរ  តើធ្វើយ៉ាងម៉េចដើម្បីឱ្យសិស្សចង់អាន ?

ចម្លើយ  . សិស្សត្រូវតែមានសៀវភៅពេញចិត្ត

. ត្រូវរៀបចំសៀវភៅឱ្យបានច្រើនកម្រិត ច្រើនប្រភេទ

. សាលារៀនមានបណ្ណាល័យ មានបណ្ណារក្សមានជំនាញដើម្បីជួយដល់អ្នកអាន ពិសេសកុមារ

. មានម៉ោងផ្លូវការ គ្រូ មាតាបិតា ជាគម្រូ នាំសិស្សអាន

. បង្កើតទម្លាប់អានដល់សិស្ស មុនចូលថ្នាក់រៀន ឬមុនម៉ោងរៀន តាមរយៈកម្រងសំណួរខ្លីៗ

. សៀវភៅ  បន្ទាប់ពីអានហើយផ្តល់ប្រយោជន៍ដល់អ្នកអាន

២.ឯកឧត្តម  **សាមីឌី ស៊ីវឌ្ឍនា**



ប្រសាសន៍ចូលរួម  មានខ្លឹមសារទាក់ទងនឹងសារៈសំខាន់នៃសៀវភៅ និងបណ្ណាល័យ  មានដូចជា៖

. សៀវភៅ ៖ ប៉ះបាន ងាយបើក ងាយប្រើ  បង្ករឱ្យមានចលនាទាំងរាងកាយនិងខួរក្បាល ងាយកត់ត្រា

. បង្ហាញការយកចិត្តទុកដាក់របស់អ្នកនិពន្ធ ទំហំ ទ្រង់ទ្រាយ ការរចនា ទំព័រ ក្រប  ប្រធានបទ

. ជាសិល្បៈនៃស្នាដៃមួយ ដែលត្រូវបានគេរក្សាទុក

.បណ្ណាល័យមានសារៈសំខាន់បំផុតទាក់ទាញសិស្សចូលមានសៀវភៅច្រើនសម្រាប់អាន

៣.  អ្នកចូលរួម



សំណួរ  តើយើងរៀបចំយន្តការយ៉ាងណាដើម្បីឱ្យគរុសិស្សបន្តការអាន នៅពេលគេចេញទៅបំពេញការងារ  ?

ចម្លើយ  . យើងមានគោលនយោបាយ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

. សាលាអនុវត្តកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំ( SBM )

.អនុវត្តគោលការណ៍ប្រសិទ្ធភាពនិងប្រសិទ្ធផលការងារ។

៤. អ្នកចូលរួមតាមអនឡាញ

សំណួរ  ស្នើសុំផ្តល់យោបល់ លើសៀវភៅដែលវាគ្មិនស្រឡាញ់និងពេញចិត្ត

ចម្លើយ . សៀវភៅដែលស្រឡាញ់និងពេញចិត្ត ទាក់ទងនឹងការប្រែប្រួលរបស់ទឹកចិត្តបុគ្គលម្នាក់ៗ ទៅតាមវ័យ តាមពេលវេលា តាមកាលៈទេសៈសង្គម និងចំណង់ចំណូលចិត្ត

. អាចមើលអ្វីដែលពាក់ព័ន្ធ នឹងមុខងារភារកិច្ច របស់យើង ពិសេសអានអ្វីក៏ដោយឱ្យតែការ អាននោះ មានតម្លៃជាមួយនឹងជីវិតរបស់យើងនាពេលបច្ចុប្បន្ន។

៥. សំណួរ ជូនឯកឧត្តម **បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី**

សំណួរ តើមូលហេតុអ្វីដែលនាំឱ្យ ឯកឧត្តម **បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ចូលចិត្តអានសៀវភៅ រហូតអាចសរសេរសៀវភៅបាន៣៤ក្បាល ដែលស្នាដៃទី៣៤ នេះ ស្តីពី " **ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ** "។

## ប្រសាសន៍បូកសរុប និងបិទកម្មវិធី



ប្រសាសន៍បូកសរុប និងបិទកម្មវិធី ទិវាជាតិអំណានលើកទី៧ ១១ មីនា ឆ្នាំ២០២២ ដោយ**ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មានខ្លឹមសារសំខាន់ ដូចខាងក្រោម ៖

. ការរៀបចំវេទិកាពិភាក្សានេះ ដើម្បីឆ្លើយតបនឹងពាក្យថា " **ការអាន លើកកម្ពស់អំណាននៅកម្ពុជា** " ចំណុចសំខាន់គឺការលើកកម្ពស់គុណភាពការអប់រំដែលនេះជាកត្តាគន្លឹះក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ បន្ទាប់ពីយើងបានរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១២ នៅឆ្នាំ២០១៤ រួចមក។ ការធ្វើកំណែទម្រង់ ក្រសួងបានចាប់ផ្តើមពីការពិនិត្យឡើងវិញ កម្មវិធីបណ្តុះបណ្តាលកុមារតូច ការរៀបចំគោលនយោបាយមត្តេយ្យសិក្សា និងមត្តេយ្យ សិក្សាសហគមន៍ ជាដើម ។

ទាក់ទងនឹងបាឋកថា ស្រាវជ្រាវ ស្តីពី " ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ " **ឯកឧត្តម បណ្ឌិតសភាចារ្យ** បង្ហាញថា ៖

. ពី០ទៅ៣ឆ្នាំ ប្រសិនបើកុមារហូបចុកមិនគ្រប់គ្រាន់ របបអាហារមិនគ្រប់គ្រាន់ ក្នុង១០០០ ថ្ងៃដំបូង និងនាំឱ្យប្រព័ន្ធខួរក្បាលមិនល្អ គឺរៀនយ៉ាងម៉េច ក៏រៀនមិនពូកែដែរ។ ដូចនេះ មាតាបិតាត្រូវយកចិត្តទុកដាក់លើការរីកលូតលាស់របស់កុមារនៅកម្រិតមត្តេយ្យសិក្សា ត្រូវបណ្តុះកុមារតូច ឱ្យចេះនិយាយ ហ៊ាននិយាយ ក្លាហាន ឯករាជ្យ។

. កុមារដែលបានរៀនឆ្លងកាត់មត្តេយ្យសិក្សា បានបង្ករជាមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ការសិក្សានៅបឋមសិក្សា បន្តទៅមធ្យម និងឧត្តមសិក្សា ។

ដូចនេះ ឪពុកម្តាយ ត្រូវបណ្តុះឱ្យកូនចេះស្រឡាញ់សៀវភៅ តាមរយៈ ការឧស្សាហ៍នាំកូនទៅបណ្ណាល័យ កន្លែងលក់សៀវភៅ អានសៀវភៅឱ្យកូនស្តាប់ ដើម្បីបង្ករឱ្យកូនស្រឡាញ់សៀវភៅ និងរីករាយអានសៀវភៅ។

ពាក់ព័ន្ធនឹងសំណួររបស់អ្នកចូលរួមតាមអនឡាញ **ឯកឧត្តម បណ្ឌិតសភាចារ្យ** មានប្រសាសន៍ថា ៖

. កាលអាយុលោក នៅ៣ ឬ ៤ ឆ្នាំ លោក ត្រូវបានម្តាយយកទៅផ្ញើឱ្យរៀននៅសាលាព្រះកែមរកត ដោយពេលនោះ រៀនតាមគេ ស្តាប់គេ រួមនឹងម្តាយរបស់លោកបានបង្រៀននៅផ្ទះផង បានធ្វើឱ្យលោកចេះអាន ។

. លោកត្រូវបានចូលរៀននៅអាយុ ៤ ឆ្នាំ ដែលមិនទាន់គ្រប់អាយុ ពេលនោះមានការលំបាកខ្លាំង រហូតដល់មធ្យមសិក្សាទើបមានការធូរស្រាល ។

. នៅទសវត្សឆ្នាំ៧០ ដោយសារសង្គ្រាម ខ្លាចបញ្ហាសង្គ្រាម ទំនេរច្រើន លោកក៏ចាប់ផ្តើមអាន និងចូលចិត្ត

អាន សៀវភៅ របស់អ្នកនិពន្ធមានស្នាដៃល្អៗក្នុងការសរសេរ ដូចជា នូ ហាច ជាដើម ។

. មូលហេតុដែលនាំឱ្យ **ឯកឧត្តម បណ្ឌិតសភាចារ្យ** ចូលចិត្តសរសេរសៀវភៅ៖ ពីមុនមានមនុស្សអត់សៀវភៅអាន នាំឱ្យទិញផង និងដើររើសសៀវភៅចាស់ៗដែលសល់ក្នុងបណ្ណាល័យផង។ ដោយសារលោកស្រឡាញ់សៀវភៅក៏មានគំនិតចាប់ផ្តើមសរសេរសៀវភៅ ដើម្បីឱ្យមានសៀវភៅច្រើន ទុកជាការចែករំលែកសម្រាប់ប្រើប្រាស់ ។

ទាក់ទងនឹងការអភិវឌ្ឍផ្នែកអំណាន ក្រសួងបានរៀបចំ ដូចជា ៖

**នៅកម្រិតបឋមសិក្សា**

. បានរៀបចំឱ្យមានកញ្ចប់អំណាន ៖ មានបង្ហាញពីវិធីសាស្ត្របង្រៀនអំណានដំបូង ដើម្បីជួយដល់ការអាន ងាយរៀន ងាយចេះប្រកប ធ្វើឱ្យគ្រូអាចគ្រប់គ្រងថ្នាក់រៀន និងនាំឱ្យគ្រូអាចក្លាយជាគ្រូល្អ

. វិធីសាស្ត្រអំណានដំបូង ដូចជាការរៀនពាក្យថ្មី ត្រូវអានឱ្យចូលពាក្យថ្មីៗ ដើម្បីទាប់ចងចាំ លែងភ្លេច

. ការអានសំខាន់ណាស់ ក្រសួងបានយកចិត្តទុកដាក់ លើកញ្ចប់អំណានពីថ្នាក់ដំបូង ថ្នាក់ទី១ ទី២ និងទី៣ ដើម្បីជាមូលដ្ឋានគ្រឹះនៃការសិក្សា របស់កុមារ

. សាលារៀន ត្រូវរៀបចំឱ្យមានបណ្ណាល័យមានបរិយាកាសល្អបង្កដល់ការអានសៀវភៅ មានសៀវភៅអាន

**នៅកម្រិតមធ្យមសិក្សា**

. ប្រើប្រាស់វិធីសាស្ត្រឱ្យសិស្សសិក្សាស្រាវជ្រាវដោយខ្លួនឯង ដោយគ្រូដាក់ប្រធានបទឱ្យសិស្សស្រាវជ្រាវ

. ឱ្យសិស្សធ្វើបទបង្ហាញ សួរដេញដោលគ្នា ឱ្យមានកម្មវិធីប្រឡងតស៊ូមតិ និងការធ្វើតែសដើមឆ្នាំ

. គ្រូដឹកនាំការងារពិភាក្សានៅក្នុងថ្នាក់ ធ្វើការងារជាក្រុម ស្រាវជ្រាវ អានសៀវភៅ សរសេរ និងធ្វើបទបង្ហាញផង នេះជាមូលដ្ឋានមួយនាំឱ្យសិស្សមានការរីកលូតលាស់បំណិនសតវត្សរ៍ទី២១

